# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

មជ្ឈមណ្ឌលអប់រំ

440 N. BROAD STREET
PHILADELPHIA, PENNSYLVANIA 19130

**ការិយាល័យនៃអគ្គនាយកផ្នែកសិក្សាធិការ**

**ការិយាល័យផ្នែក កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ**

ជូនចំពោះ មាតាបិតា និង អាណាព្យាបាលៈ

គោលបំណងនៃលិខិតនេះគឺដើម្បីជូនដំណឹងដល់លោកអ្នកអំពីការសម្រេចក្នុងពេលថ្មីៗនេះ ក្នុងការពន្យារពេលប្រើ ការប្រឡង ឃីស្តូន/Keystone Exams ដែលជាការតម្រូវនៃការបញ្ចប់ការសិក្សាសម្រាប់សិស្ស រហូតដល់ឆ្នាំសិក្សា ២០១៩-២០។

នៅថ្ងៃទី៦ ខែកុម្ភៈ ២០១៧ ញត្តិរដ្ឋសភា លេខ ១៧៨ បានក្លាយជាច្បាប់។ តម្រូវការមួយនៃច្បាប់នេះគឺ ពន្យារពេលប្រើការប្រឡង ឃីស្តូន (ពិជគណិត ជីវវិជ្ជា និង អក្សរសាស្ត្រ) ដែលជាការតម្រូវនៃការបញ្ចប់ការសិក្សាសម្រាប់សិស្ស រហូតដល់ឆ្នាំសិក្សា ២០១៩-២០។ ទោះជាយ៉ាងដូច្នេះក្តី ច្បាប់សម្រាប់ជោគជ័យរបស់សិស្សគ្រប់រូប/The Every Student Succeeds Act (ESSA) នៅតែតម្រូវឲ្យសិស្សវិទ្យាល័យទាំងអស់ប្រឡង គណិតវិទ្យា និង ការអាន ហើយនៅចន្លោះពេលឡើងថ្នាក់ម្តងៗ ត្រូវប្រឡង មុខវិជ្ជាវិទ្យាសាស្ត្រ។ នេះមានន័យថា សិស្សនៅតែតម្រូវឲ្យប្រឡងឃីស្តូនម្តងៗ។

យោងទៅលើ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា (PDE) មូលហេតុនៃការពន្យាការប្រឡងឃីស្តូនដែលជាតម្រូវការនៃការបញ្ចប់ការសិក្សាទូទាំងរដ្ឋ គឺមានដូចតទៅៈ

(១) សិស្សជាច្រើនមិនបានបង្ហាញឲ្យឃើញថាមានចំណេះដឹងគ្រប់គ្រាន់ នៅពេលប្រឡងមុខវិទ្យាឃីស្តូនទីមួយៗ (ពិជគណិត១ ជីវវិជ្ជា អង់គ្លេស/អក្សរសិល្ប៍) ទោះជាបានប្រឡងម្តងទៀតក្តី។

(២) ជម្រើសផ្សេងទៀតសម្រាប់សិស្សដែលមិនបានបង្ហាញឲ្យឃើញថាមានចំណេះដឹងគ្រប់គ្រាន់ នៅពេលប្រឡងឃីស្តូនគឺ មានតម្លៃថ្លៃ អស់ពេលវេលាច្រើន និង ហួសពីសមត្ថភាពរបស់ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេនញ៉ា និង ក្រសួងអប់រំតាមតំបន់ ក្នុងការឆ្លើយតប។

នៅខាងក្រោយលិខិតនេះ លោកអ្នកនឹងឃើញមាន សំណួរដែលគេឧស្សាហ៍សួរ – កំណែថ្មីនៃ មាត្រា 4 SB ១៧៨ (Chapter 4 SB 178 Update) ដែលពន្យល់ពីការប៉ះពាល់ដល់សិស្សានុសិស្ស។ សូមពិនិត្យមើល សំណួរដែលគេឧស្សាហ៍សួរដូចតទៅនេះ ដោយប្រុងប្រយ័ត្ន ហើយពិភាក្សាជាមួយកូនរបស់លោកអ្នក។

បើសិនជាលោកអ្នកមានសំណួរអ្វី សូមអ៊ីមែលទៅ assessment@philasd.org។ ព័ត៌មានបន្ថែមសម្រាប់មាតាបិតា (បានបកប្រែជាប្រាំបី ភាសា) អំពីការប្រឡង PSSA និង Keystone អាចឃើញមាននៅក្នុងវិបសៃនៃ កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ របស់ក្រសួងអប់រំៈ https://www.philasd.org/curriculum/assessment/។

សូមអរគុណជាអនេកប្បការ។

ដោយសេចក្តីស្មោះស្ម័គ្រ

Christopher Shaffer
នាយករង, ការិយាល័យផ្នែក កម្មវិធីសិក្សា ការបង្ហាត់បង្រៀន និង ការវាយតម្លៃ

**កំណែថ្មីនៃ មាត្រា 4 SB ១៧៨ (Chapter 4 SB 178 Update)**

## សំណួរដែលគេឧស្សាហ៍សួរ

### អារម្ភកថា

ជាមួយនឹងញត្តិរបស់រដ្ឋសភា លេខ ១៧៨ (Senate Bill 880) ដែលក្លាយជាច្បាប់ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ការប្រើប្រាស់ការប្រឡង ឃីស្តូន សម្រាប់ជាតម្រូវការនៃការបញ្ចប់ការសិក្សារបស់រដ្ឋ ឬ ជាខ្នាតគំរូ ដែលគេត្រូវការសម្រាប់ការចូលរួមក្នុងការវាយតម្លៃដែលផ្អែកទៅលើគម្រោងសិក្សាជាក់ស្តែង ត្រូវព្យួរទុករហូតដល់ឆ្នាំសិក្សា ២០១៩-២០២០។ សំណួរដែលគេឧស្សាហ៍សួរខាងក្រោមនេះ បានរៀបចំឡើងដើម្បីបកស្រាយបំភ្លឺនូវការពាក់ព័ន្ធនៃច្បាប់ HB 178។

### ការប៉ះពាល់ដល់សិស្សដែលនឹងបញ្ចប់ការសិក្សាមុនឆ្នាំ២០២០។

១. **តើគេនៅតែតម្រូវឲ្យចូលរួមក្នុង ការប្រឡង ឃីស្តូន (Keystone) ទៀតដែរឬទេ?**
ការតម្រូវរបស់រដ្ឋសហព័ន្ធ ដែលទាក់ទងនឹងការវាយតម្លៃរបស់រដ្ឋ គ្មានការផ្លាស់ប្តូរទេ។ ក្នុងខណៈដែលគេមិនតម្រូវឲ្យសិស្សដែលបញ្ចប់ការសិក្សាមុនឆ្នាំ២០២០ បង្ហាញភាពស្ទាត់ជំនាញក្នុងការប្រឡង ឃីស្តូន ដើម្បីតម្រូវតាមសេចក្តីត្រូវការនៃការបញ្ចប់ការសិក្សារបស់រដ្ឋទៀតទេ ប៉ុន្តែការចូលរួមក្នុងការវាយតម្លៃរបស់រដ្ឋ នៅតែជាតម្រូវការរបស់សហព័ន្ធ ដដែល។

២. **បើសិនជាសិស្សបញ្ចប់ការសិក្សាមុនឆ្នាំ២០២០ ហើយមិនទាន់ទទួលបានកម្រិតស្ទាត់ជំនាញក្នុងការប្រឡង ឃីស្តូន តើគេនៅតែតម្រូវឲ្យមានការបង្ហាត់បង្រៀនបន្ថែម ដែរឬទេ?**
សាលាគប្បីផ្តល់ការបង្ហាត់បង្រៀនបន្ថែម ដល់សិស្សដែលត្រូវបានគេជ្រើសរើសឲ្យប្រឡង ឃីស្តូន ឡើងវិញ កាលពីមុនពួកគេបានប្រឡងម្តងហើយ ប៉ុន្តែមិនបានបង្ហាញថាមានចំណេះដឹងគ្រប់គ្រាន់ ប៉ុន្តែគេមិនតម្រូវឲ្យសិស្សត្រូវតែចូលរួមការបង្ហាត់បង្រៀនបន្ថែមនោះទេ។ ការរៀបចំការបង្ហាត់បង្រៀនបន្ថែម នៅតែជា ការសម្រេចរបស់កន្លែងនីមួយៗ។

៣. **បើសិនជាសិស្សបញ្ចប់ការសិក្សាមុនឆ្នាំ២០២០ ហើយមិនទាន់ទទួលបានកម្រិតស្ទាត់ជំនាញក្នុងការប្រឡង ឃីស្តូន ក្រោយពីបានប្រឡងម្តងហើយ តើគេតម្រូវឲ្យប្រឡងម្តងទៀតដែរឬទេ?**
គេមិនតម្រូវឲ្យប្រឡងម្តងទៀតទេ។ ទោះជាដូច្នេះក៏ដោយ សិស្សអាចប្រឡងម្តងទៀតបាន។ បើសិនជាសិស្សត្រូវប្រឡងម្តងទៀត សាលាត្រូវតែផ្តល់ការបង្ហាត់បង្រៀនបន្ថែម មុនពេលប្រឡងម្តងទៀត។

៤. **និយាយដោយខ្លី តើផ្នែកណាមួយនៃ មាត្រា ៤ ដែលត្រូវគេព្យួរទុក?**
ខាងក្រោមនេះ បញ្ជាក់ពីមូលហេតុនៃការព្យួរទុកសិន ចំពោះសិស្សដែលបញ្ចប់ការសិក្សានៅឆ្នាំ ២០១៨ និង ២០១៩៖
   - ក. តម្រូវការនៃការបញ្ចប់ការសិក្សារបស់រដ្ឋ ដើម្បីបង្ហាញពីការស្ទាត់ជំនាញក្នុងការប្រឡង ឃីស្តូន ឬ ការវាយតម្លៃដែលផ្អែកទៅលើគម្រោងសិក្សាជាក់ស្តែង ត្រូវគេព្យួរទុកសិន។
   - ខ. សម្រាប់សិស្សដែលមិនបានទទួលកម្រិតស្ទាត់ជំនាញ ក្រោយពីបានប្រឡង ឃីស្តូន ពីរដងរួចហើយ គេមិនតម្រូវឲ្យធ្វើការវាយតម្លៃ ដែលផ្អែកទៅលើគម្រោងសិក្សាជាក់ស្តែងនោះទេ។
   - គ. គេមិនតម្រូវឲ្យសិស្សចូលរួមក្នុងការបង្ហាត់បង្រៀនបន្ថែមទៀតទេ។ ទោះជាយ៉ាងដូច្នេះក៏ដោយ សាលាត្រូវតែផ្តល់ការបង្ហាត់បង្រៀនបន្ថែម ដែលចាត់ទុកថាជាជម្រើសមួយ។

### ការប៉ះពាល់ដល់សិស្សដែលនឹងបញ្ចប់ការសិក្សានៅឆ្នាំ២០២០ ឬ ក្រោយពីឆ្នាំនេះ។

១. **តើគេនៅតែតម្រូវឲ្យចូលរួមក្នុងការប្រឡង ឃីស្តូន (Keystone) ទៀតដែរឬទេ?**
ការតម្រូវរបស់រដ្ឋសហព័ន្ធ ដែលទាក់ទងនឹងការវាយតម្លៃរបស់រដ្ឋ គ្មានការផ្លាស់ប្តូរអ្វីទេ។ សិស្សដែលនឹងបញ្ចប់ការសិក្សានៅឆ្នាំ២០១៩ ឬ ក្រោយពីឆ្នាំនេះ នៅតែតម្រូវឲ្យចូលរួកការវាយតម្លៃរបស់រដ្ឋដដែល ដែលបច្ចុប្បន្ននេះគឺជាការប្រឡងឃីស្តូន។ សិស្សបញ្ចប់ការប្រឡងឃីស្តូននៅចុងបញ្ចប់នៃការសិក្សាមុខវិជ្ជា ពិជគណិត១ ជីវវិទ្យា ឬ អង់គ្លេស២។

២. **បើសិនជាសិស្សបញ្ចប់ការសិក្សានៅឆ្នាំ ២០២០ ឬក្រោយពីឆ្នាំនេះ មិនទាន់ទទួលបានកម្រិតស្ទាត់ជំនាញក្នុងការប្រឡង ឃីស្តូន ក្រោយពីបានប្រឡងម្តងហើយ តើគេតម្រូវឲ្យប្រឡងម្តងទៀតដែរឬទេ?**

បច្ចុប្បន្ននេះ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា សំណូមពរឲ្យសិស្សដែលបញ្ចប់ការសិក្សានៅឆ្នាំ២០២០ ឬក្រោយពីឆ្នាំនេះ ដែលបានរៀនចប់មុខវិទ្យា ប៉ុន្តែមិនបង្ហាញពីការស្ទាត់ជំនាញក្នុងការការប្រឡង ឃីស្តូន ប្រឡងម្តងទៀត ដើម្បីផ្តល់ឱកាសដល់សិស្សឲ្យបង្ហាញពីការស្ទាត់ជំនាញ។ សាលាត្រូវតែផ្តល់ការបង្ហាត់បង្រៀនបន្ថែមដល់សិស្ស មុនពេលប្រឡងម្តងទៀត ក៏ប៉ុន្តែ ដើម្បីអាចប្រឡងម្តងទៀត គេមិនតម្រូវឲ្យសិស្សត្រូវតែចូលរួមក្នុងការបង្ហាត់បង្រៀនបន្ថែមនោះទេ។ ការរៀបចំឲ្យមានការបង្ហាត់បង្រៀនបន្ថែម នៅតែជាការសម្រេចចិត្តរបស់សាលា។

៣. **បើសិនជាសិស្សបញ្ចប់ការសិក្សានៅឆ្នាំ ២០២០ ឬក្រោយពីឆ្នាំនេះ ហើយមិនទាន់ទទួលបានកម្រិតស្ទាត់ជំនាញក្នុងការប្រឡង ឃីស្តូន តើគេតម្រូវឲ្យសិស្សធ្វើកិច្ចការអ្វីមួយដើម្បីឲ្យគ្រូធ្វើការវាយតម្លៃ (Project Based Assessment) ដែរឬទេ?**

គ្មានសិស្សណាម្នាក់ចូលរួមធ្វើកិច្ចការអ្វីមួយដើម្បីឲ្យគ្រូធ្វើការវាយតម្លៃ នោះទេ ដរាបណាគ្មានការណែនាំពីការផ្លាស់ប្តូរច្បាប់បច្ចុប្បន្ន ដែលផ្តល់ឲ្យដោយ ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា។

៤. **បន្ទាប់មក មានអ្វីទៀត?**

ក្រសួងអប់រំនឹងបន្តការទាក់ទងជាមួយ ក្រសួងអប់រំរដ្ឋផិនស៊ីលវេនញ៉ា និង ភ្នាក់ងាររដ្ឋ ដើម្បីតាមដានការអភិវឌ្ឍន៍ ច្បាប់នៃមាត្រា ៤ ដែលបង្គាប់ពី ការប្រឡង និង ការបញ្ចប់ការសិក្សា។ នៅពេលណាដឹងថាមានការផ្លាស់ប្តូរច្បាប់បច្ចុប្បន្ន ក្រសួងនឹងជម្រាបព័ត៌មានជូនដល់មាតាបិតា/អាណាព្យាបាល។